# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ ការវិភាគរកការពិតអំពីថ្ងៃ៧មករា១៩៧៩

**Website: www.hoksavann.org**

ថ្ងៃទី៩ មករា ២០១០



ដើម្បីរកភាពពិតនៃថ្ងៃ៧មករា១៩៧៩ យើងគួរលើកយកព្រឹត្តិការណ៍ពីរប្រការមកវិភាគរកការពិត គឺទីមួយវៀតណាមនិងកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) មានទំនាស់គ្នា និងទីពីររបបខ្មែរក្រហមមានបញ្ហាផ្ទៃក្នុង ។

អ្នកណាក៏ដឹងដែរថា វៀតណាមជាគ្រូខ្មែរក្រហម បានបង្ហាត់ទ័ពខ្មែរក្រហមតាំងពីឆ្នាំ១៩៧០មកដើម្បីវាយកងទ័ពសាធារណរដ្ឋខ្មែររបស់លោកសេនាប្រមុខលន់-នល់ ។ ក្រោយមកខ្មែរក្រហមជាកូនសិស្សបានបង្កើតសត្រូវជាមួយវៀតណាមនៅឆ្នាំ១៩៧៧ ។ ខ្មែរក្រហមបានរុករកជនជាតិវៀតណាមនៅតាមសហករណ៍ ដើម្បីកំទេចចោល ។ មិនតែប៉ុណ្ណោះខ្មែរក្រហមបានលើកទ័ពចូលជ្រៅទៅប្រទេសវៀតណាម ហើយបានវាយកំទេចភូមិវៀតណាមខ្លះ ដែលធ្វើឲ្យខូចខាតទ្រព្យសម្បត្តិ និងជីវិតជនជាតិវៀតណាមខ្លះ ។ ដំបូងឡើយចិនកុម្មុយនិស្តនិងវៀតណាមជួយខ្មែរក្រហមទាំងពីរនាក់ ។ ក្រោយមកចិននិងវៀតណាមមានទំនាស់គ្នាពីកោះនៅក្នុងសមុទ្រ ។ ពេលនោះខ្មែរក្រហមបានងាកទៅរកចិនកាន់តែខ្លាំង ហើយយកវៀតណាមជាសត្រូវ ។ អាកប្បកិរិយារបស់ខ្មែរក្រហមបែបនេះ បានធ្វើឲ្យវៀតណាមចងគំនុំជាមួយខ្មែរក្រហមកាន់តែខ្លាំងឡើង ។

ចំណែកផ្ទៃក្នុងខ្មែរក្រហម ក៏មានការបែកបាក់គ្នា ។ មិនត្រឹមតែបោសសំអាតរបបសាធារណរដ្ឋខ្មែរទេ ខ្មែរក្រហមបានបោសសំអាតក្នុងជួរបក្សរបស់ខ្លួន ដោយចោទថាក្បត់បក្ស ។ ខ្មែរក្រហមនៅតំបន់បូព៌ានៃប្រទេសកម្ពុជាបានរត់ទៅប្រទេសវៀតណាម ព្រោះខ្លាចប៉ុល-ពតសម្លាប់ ។ ជាឱកាសល្អរបស់វៀតណាម បានចងក្រងខ្មែរក្រហមដែលរត់ទៅនោះ ឲ្យធ្វើបដិវត្តន៍រំលំខ្មែរក្រហម ហើយវៀតណាមខ្លួនឯងបានលើកទ័ពជាងពីរសែននាក់ ចូលមកប្រទេសកម្ពុជាផ្តួលរំលំខ្មែរក្រហមតែម្តងទៅ ។

សំនួរថា ៖

- បើខ្មែរក្រហមមិនយកវៀតណាមជាសត្រូវទេ តើវៀតណាមលើកទ័ពមកកំចាត់ខ្មែរក្រហម ដែលនាំឲ្យមានថ្ងៃ៧មករា១៩៧៩ឬទេ ?

- បើខ្មែរក្រហមប៉ុល-ពតមិនចោទខ្មែរក្រហមនៅបូព៌ា ដែលសព្វថ្ងៃក្លាយជាបក្សប្រជាជនកម្ពុជាថាជាខ្មាំងទេ តើកម្មាភិបាលតំបន់បូព៌ានោះរត់ទៅប្រទេសវៀតណាមឬទេ ?

បើសាធារណរដ្ឋសង្គមនិយមវៀតណាម វាយរំលំខ្មែរក្រហមប៉ុល-ពតដែលមិនស្តាប់បង្គាប់ខ្លួន ហើយតែងតាំងខ្មែរក្រហម (គណបក្សប្រជាជនកម្ពុជា) ឲ្យកាន់អំណាចខ្មែរវិញ ដូច្នេះត្រូវបដិសេធពាក្យថា ជាបេសកកម្មអធនអន្តរជាតិ មកជួយរំដោះប្រជាពលរដ្ឋខ្មែរពីបនប្រល័យពូជសាសន៍ខ្មែរក្រហម ដោយទាហានស្ម័គ្រចិត្តវៀតណាម ។ បានសេចក្តីថា វៀតណាមដែលវាយរំលំខ្មែរក្រហម ពុំមែនមូលហេតុមកពីការអាណិតអាសូរប្រជាពលរដ្ឋខ្មែរដោយសារខ្មែរក្រហមសម្លាប់ខ្មែរនោះទេ តែដោយមូលហេតុខ្មែរក្រហមយកខ្លួនជាសត្រូវវិញទេ ។ យើងនៅចាំបានថា នៅឆ្នាំ១៩៧៧ គឺពេលដែលខ្មែរក្រហមនិងវៀតណាមពុំទាន់មានទំនាស់គ្នា មានសារពត៌មានមួយនៅប្រទេសអង់គ្លេសបានផ្សាយតាមសំដីអ្នកភៀសខ្លួនខ្មែរថា នៅប្រទេសកម្ពុជាមានការកាប់សម្លាប់ប្រជាពលរដ្ឋខ្មែរដោយរបបខ្មែរក្រហម ហើយសារពត៌នោះបានអំពាវនាវ ឲ្យអន្តរជាតិធ្វើអន្តរាគមន៍ដោះស្រាយបញ្ហាការកាប់សម្លាប់នេះ ។ ភ្លាមនោះ វៀតណាមបាននិយាយប្រឆាំងថា **នេះជាកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ប្រទេសណាក៏ដោយមិនត្រូវលូកដៃចូលមកក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្មែរឡើយ** ។ នេះជាការការពារខ្មែរក្រហមដើម្បីបិទបាំងការកាប់សម្លាប់របស់ខ្មែរក្រហម ។ ត្រង់នេះបញ្ជាក់ថា ទោះបីខ្មែរក្រហមកាប់សម្លាប់ខ្មែរអស់ពីនគរកម្ពុជាក៏ដោយ ក៏វៀតណាមគ្មានរវល់ឈឺក្បាលអ្វីឡើយ បើខ្មែរក្រហមនៅតែស្តាប់បង្គាប់ខ្លួន ។ ចំពោះកម្មាភិបាលខ្មែរក្រហមដែលរត់ទៅវៀតណាម ដែលសព្វថ្ងៃជាគណបក្សប្រជាជនកម្ពុជានោះ ពុំមែនរត់គេចខ្លួនដោយពុំពេញចិត្តរបបកុម្មុយនិស្តឡើយ តែរត់គេចខ្លួនពីការដេញសម្លាប់នៃពួកខ្មែរក្រហមប៉ុល-ពតវិញទេ ។ បានសេចក្តីថា បើប៉ុល-ពតគ្មានផែនការកាប់សម្លាប់ទេ ខ្មែរក្រហមនៅតំបន់បូព៌ានឹងនៅតែកាន់របបកុម្មុយនិស្តជាមួយខ្មែរក្រហមប៉ុល-ពតដដែល ។ ភស្តុតាងក្នុងអំឡុងពេលឆ្នាំ១៩៩០ នៅពេលមានរាជរដ្ឋាភិបាលចំរុះកើតឡើង គណៈប្រជាជននៅតែធ្វើពិធីរំឭកខួបថ្ងៃទី១៧មេសា១៩៧៥ គឺជាថ្ងៃដែលពួកខ្មែរក្រហមមានជ័យជំនះលើរបបសាធារណរដ្ឋខ្មែរ ។ ក្រោយមកទើបគណបក្សប្រជាជនឈប់ធ្វើបុណ្យរំឭកថ្ងៃ១៧មេសា១៩៧៥ ហើយទើបចាប់ធ្វើបុណ្យរំឭកថ្ងៃ៧មករា១៩៧៩វិញជាបន្តទៅទៀត ។

យើងសូមទទួលស្គាល់ថ្ងៃ៧មករា១៩៧៩ វៀតណាមបានផ្តួលរំលំរបបខ្មែរក្រហម ទោះបីបំណងណាក៏ដោយ តែបានជួយរំដោះប្រជាពលរដ្ឋខ្មែរដែលខ្មែរក្រហមមិនទាន់សម្លាប់ កុំឲ្យស្លាប់តទៅទៀត ។ យើងក៏បានធ្វើការកត់សំគាល់ថា នៅពេលដែលខ្មែរក្រហមកំពុងតែកាប់សម្លាប់នោះ គ្មានអន្តរជាតិឬប្រទេសណាមួយជួយធ្វើអន្តរាគមន៍ ជួយបង្អាក់ដំណើរនៃការកាប់សម្លាប់នេះឡើយ ។ ខ្លះយល់ថា ពេលដែលខ្មែរក្រហមឡើងកាន់អំណាចពីឆ្នាំ១៩៧៥នោះ ខ្មែរក្រហមបានបិទទ្វារ

ពិភពខាងក្រៅមិនឲ្យចូលទៅយកពត៌មានឡើយ ។ ដូច្នេះអន្តរជាតិពុំបានដឹងច្បាស់អំពីភាពឃោរឃៅរបស់ខ្មែរក្រហមនេះឡើយ ។ បើបានដឹងច្បាស់លាស់ គេនឹងធ្វើអន្តរាគមន៍អំពីអំពើព្រៃផ្សៃនេះបែបណាមួយ ។ អ្នកគាំទ្រថ្ងៃ៧មករាពោលថា ដោយសារតែរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា រួមជាមួយទាហានស្ម័គ្រចិត្តវៀតណាម ចូលមកវាយរំលំរបបប៉ុល-ពតនេះហើយ ដែលធ្វើឲ្យខ្មែររស់ឡើងវិញ ។ បើគ្មានថ្ងៃ៧មករា១៩៧៩នេះទេ អ្វីៗក៏គ្មានដូចសព្វថ្ងៃនេះដែរ ។ រហូតធ្វើឲ្យអ្នកកាន់អំណាចជាន់ខ្ពស់ខ្មែរបច្ចុប្បន្នពោលតិះដៀលថា អ្នកដែលប្រឆាំងនឹងថ្ងៃ៧មករា១៩៧៩ គឺជាសត្វ ។

ផ្ទុយទៅវិញ អ្នកដែលមិនគាំទ្រថ្ងៃ៧មករា១៩៧៩ តែងចោទថាថ្ងៃ៧មករា១៩៧៩ ជាការឆ្លៀតឱកាសឈ្លានពានរបស់វៀតណាម បង្កើតសហព័ន្ធកុម្មុយនិស្តឥណ្ឌូចិនជំនួសបារាំងតាមផែនការហូ-ជីមិញ គឺវៀតណាម កម្ពុជា និងលាវ ក្រោមការត្រួតត្រារបស់វៀតណាម ។ អង្គការសហប្រជាជាតិក៏បានថ្កោលទោសនៃការឈ្លានពាននេះ ។ អ្នកប្រឆាំងនឹងថ្ងៃ៧មករាបានសង្កេតឃើញថា ការចូលមកឈ្លានពានប្រទេសកម្ពុជាបានបង្កើតសោកនាដកម្មជាថ្មីទៀត ព្រោះវៀតណាមបានចូលមកផ្តួលរំលំខ្មែរក្រហមហើយ មិនបានត្រឡប់ទៅវៀតណាមវិញ ប្រគល់ឲ្យអង្គការសហប្រជាជាតិជួយពលរដ្ឋខ្មែរជាបន្តទៀតឡើយ ។ វៀតណាមបានត្រួតត្រាលើប្រទេសកម្ពុជា មានលក្ខណៈជាចៅហ្វាយធ្វើអាណានិគមលើប្រទេសកម្ពុជាគ្រប់វិស័យសេដ្ឋកិច្ច វប្បធម៌ នយោបាយ អស់រយៈពេលជាង១០ឆ្នាំ ។ ភោគទ្រព្យខ្មែរបានប្រមូលទៅប្រទេសវៀតណាម ចាប់អ្នកស្នេហាជាតិខ្មែរដាក់គុក សម្លាប់ ជាពិសេសផែនការក-៥នៅដើមឆ្នាំ១៩៨៤ (mur de bambou) ខ្មែរត្រូវស្លាប់រាប់សែននាក់ ។ អាណិកជនយួនបានហូរចូលមកប្រទេសកម្ពុជា ដោយគ្មានការត្រួតពិនិត្យ ។ ទឹកដីខ្មែរខ្លះទាំងដីគោកដីសមុទ្របានត្រូវបាត់បង់ ។ល។ នេះជាពាក្យចោទរបស់ខ្មែរដែលប្រឆាំងនឹងថ្ងៃ៧មករា១៩៧៩ ដោយប្រៀបធៀបការជួយនេះ ទៅនឹងបុរសម្នាក់ទាញសត្វកង្កែបចេញពីមាត់ពស់ ។ កង្កែបនោះផុតពីស្លាប់ដោយសារពស់ តែសត្វកង្កែបនោះត្រូវស្លាប់ដោយសារមនុស្សនោះសម្លាប់ធ្វើម្ហូប ។

ចំពោះខ្មែរស្លាប់រាប់លាននាក់នេះ ខ្មែរក្រហមបានចោទថា ពុំមែនខ្លួនទេជាអ្នកសម្លាប់ គឺភ្នាក់ងារវៀតណាមបង្កប់ខ្លួនដូចក្នុងសៀវភៅយាយទៀងសរសេរ ឆ្លើយទៅនឹងចំណងជើងសៀវភៅថា «អង្គការជានរណា ?» អង្គការគឺយួន ។ ដូច្នេះមេខ្មែរក្រហមដែលកំពុងជាប់ចោទនៅក្នុងរង្វង់ក្រចកសេះ ហ៊ានឆ្លើយដូច្នេះដូចពាក្យនៅក្រៅរង្វង់ក្រចកសេះឬទេ ?

តើសន្ធិសញ្ញាសន្តិភាពថ្ងៃ២៣តុលា១៩៩១ ក្រោមកិច្ចចាត់ចែងរបស់អង្គការសហប្រជាជាតិ មានប្រយោជន៍អ្វីខ្លះដល់ប្រទេសកម្ពុជា ? មានប្រយោជន៍សំខាន់ណាស់ គឺលះបង់របបកុម្មុយនិស្ត កាន់របបប្រជាធិបតេយ្យសេរីពហុបក្ស ប្រទេសកម្ពុជាគ្មានទ័ពបរទេស ដកអាវុធចេញពីភាគីខ្មែរទាំងបួន បោះឆ្នោតដោយសេរីនិងយុត្តិធម៌ កសាងប្រទេសកម្ពុជាឡើងវិញ ជាពិសេសធានាឯករាជ្យ អធិបតេយ្យជាតិ និងបូរណភាពទឹកដីនៃប្រទេសកម្ពុជា ។ ខ្មែរបើគ្មានសន្ធិសញ្ញានេះទេ ខ្មែរនឹងក្លាយជាប្រទេសដូចជាប្រទេសលាវ ។ ប៉ុន្តែស្ថានភាពនៃប្រទេសលាវផ្សេងពីប្រទេសខ្មែរ ប្រទេសលាវគ្មានចលនាតស៊ូបានជាលាវត្រូវវៀតណាមត្រួតត្រារហូតដល់សព្វថ្ងៃនេះ ។ ចំណែកប្រទេសកម្ពុជាជាគូប្រជែង គឺមានចលនាតស៊ូ ហើយជាកុសលល្អរបស់កម្ពុជា ដោយប្រទេសកុម្មុយនិស្តសហភាពសូវៀតបានដួលរលំ ហើយបង្ខំចិត្តឲ្យវៀតណាមដកទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជានៅខែតុលា១៩៨៩ ដោយពុំមានថវិកាចិញ្ចឹមទ័ព ។បញ្ហាទាំងនេះហើយបានជាគ្រប់ភាគីខ្មែរ និងអ្នកនៅពីក្រោយខ្នងខ្មែរ សុខចិត្តឲ្យខ្មែររួបរួមគ្នាបង្កើតសុខសន្តិភាពឲ្យដល់ប្រទេសកម្ពុជាដ៏អភ័ព្វ គឺកិច្ចព្រមព្រៀងថ្ងៃ២៣តុលា១៩៩១នេះឯង ។

តាមការរៀបរាប់មកហើយបញ្ជាក់ថា អ្នកដែលប្រឆាំងនឹងថ្ងៃ៧មករា១៩៧៩ គ្មានអ្វីក្រៅពីបារម្ភពីឥទ្ធិពលវៀតណាមដែលនាំឲ្យខ្មែរបាត់បង់ឯករាជ្យ អធិបតេយ្យជាតិ និងបូរណភាពទឹកដី ។ ដូច្នេះដើម្បីបន្ថយការប្រឆាំង ឬបំបាត់ការប្រឆាំងគណបក្សប្រជាជនកម្ពុជាដែលកាន់អំណាច គប្បីដកខ្លួនឲ្យឆ្ងាយពីឥទ្ធិពលវៀតណាម ហើយពិនិត្យមើលឡើងវិញនូវបង្គោលព្រំដែនខ្មែរ-វៀតណាមចំនួន១៩០ដែលបោះរួចហើយ ។ ព្រោះអ្នករិះគន់មានការសង្ស័យអំពីភាពពុំត្រឹមត្រូវ ដោយឃើញភស្តុតាងបង្គោលតម្រុយលេខ១៨៥ បោះចូលមកដីស្រែរបស់ប្រជាកសិករក្នុងស្រុកចន្ទ្រាខេត្តស្វាយរៀង ។ បង្គោលកន្លែងខ្លះជាជាទីព្រៃគ្មានពលរដ្ឋខ្មែររស់នៅ អាចបោះចូលមកដីខ្មែរកាន់តែជ្រៅ ហើយគួរពិនិត្យមើលបង្គោលចាស់ខ្លះ អាចយួនលួចបោះមុនគណៈកម្មាធិការខ្មែរ-វៀតណាមចុះទៅពិនិត្យ ។ ការពិនិត្យមើលឡើងវិញនេះ គួរចូលរួមដោយគណបក្សប្រឆាំង អង្គការក្រៅរដ្ឋាភិបាល ជាពិសេសគណៈកម្មាធិការព្រំដែនកម្ពុជានៅប្រទេសបារាំង ដែលមានលោកស៊ាន-ប៉េងសែជាប្រធាន ។ បើពិបាកនិយាយវៀតណាម គួរពឹងច្បាប់អន្តរជាតិតែម្តង ហើយផែនទីជាផ្លូវការ គឺផែនទីឆ្នាំ១៩៦៤ដែលដំកល់នៅអង្គការសហប្រជាជាតិ ពុំមែនធ្វើតាមសន្ធិសញ្ញាឆ្នាំ១៩៨៥ ដែលធ្វើឲ្យស្របច្បាប់នៅឆ្នាំ២០០៥ ដែលហៅថាសន្ធិសញ្ញាបំពេញបន្ថែមនោះឡើយ ។ ឯកោះទាំងឡាយដូចជាកោះត្រល់ជាដើម ក៏គួរសើរើពិនិត្យឡើងវិញ ។ អន្តោប្រវេសន៍វៀតណាមខុសច្បាប់ ត្រូវពិនិត្យហើយធ្វើតាមច្បាប់ជាបន្ទាន់ ។

ដើម្បីបន្ធូរភាពតានតឹងខាងផ្លូវនយោបាយ តុលាការខេត្តស្វាយរៀងគួរដកពាក្យបណ្តឹងប្រជាពលរដ្ឋ អំពីបញ្ហាដកបង្គោលតម្រុយព្រំដែននៅស្រុកចន្ទ្រាខេត្តស្វាយរៀង ព្រោះប្រជាពលរដ្ឋគ្មានកំហុសអ្វីទេ គ្រាន់តែលោកការពារដីស្រែរបស់ខ្លួនដោយក្រសួងមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាលមិនបានធ្វើសហការជាមួយពលរដ្ឋ ប្រាប់លោកឲ្យដឹងអំពីបំណងនៃការបោះបង្គោលតម្រុយនេះ ។ តាមពិតជាកំហុសរបស់ក្រសួងមានសមត្ថកិច្ចវិញទេ ។ សូមកុំធ្វើតាមការញុះញង់របស់បរទេស ដែលធ្វើឲ្យខ្មែរបែកបាក់គ្នា ។ កុំធ្វើអ្វីប្រកបដោយលោភៈ ទោសៈ មោហៈ ។ ធ្វើអ្វីត្រូវប្រើវិចារណញ្ញាណ ។ ត្រូវតែបើកសិទ្ធិឲ្យប្រជាពលរដ្ឋបញ្ចេញមតិ ស្របទៅតាមរដ្ឋធម្មនុញ្ញ ដោយគ្មានការភ័យខ្លាច គ្មានការចាប់ចង ។ សូមក្រឡេកមើលគណបក្សភឿថៃ ជាគណបក្សប្រឆាំងមិនកាន់អំណាចបានធ្វើបាតុកម្ម អាចផ្សាយវិទ្យុ ទូរទស្សន៍ សារពត៌មាន ។ អាចឆ្លងមកប្រទេសកម្ពុជាជួបលោកថាក់ស៊ីនប្រឆាំងរដ្ឋាភិបាល ។ អ្នកកាន់អំណាចថៃមិនប្រើហិង្សា ឬដាក់ពាក្យប្តឹងគណបក្សប្រឆាំងនោះវិញឡើយ ។៚

❑